# សិលាចារឹករកឃើញថ្មី នៅភូមិរំចេក ឃុំត្នោត

ការសិក្សាសិលាចារឹកខ្មែរ មានប្រវត្តិចាប់ផ្ដើមតាំងពីចុងស.វ.ទី១៩ និងមានសន្ទុះចាប់តាំងពីដើមស.វ.ទី២០មក។ ចំនួនសិលាចារឹកក៏បានរកឃើញជាបន្តបន្ទាប់ ទាំងសិលាចារឹកដែលចារនៅតាមប្រាសាទ ថ្មភ្នំ សសរស្ដម្ភ ឬសន្ទឹករាងជាសីមាជាដើម ដែលខ្លះបានកប់នៅក្នុងដី ដែលជាអតីតទីតាំងបុរាណដ្ឋាន។ មកទល់បច្ចុប្បន្ននេះ សិលាចារឹកខ្មែរដែលបានចុះក្នុងបញ្ជីសារពើភណ្ឌសិលាចារឹក របស់សាលាបារាំងចុងបូព៌ាប្រទេសមានរហូតដល់ K.១៥៧០ ដែលចំនួននេះនឹងត្រូវបន្តកើនឡើងជាបន្តទៅទៀត ដ្បិតសិលាចារឹកខ្មែរនៅតែបន្តរកឃើញជារឿយៗរហូតមក។ ជាក់ស្ដែង នាពេលថ្មីៗនេះ កាលពីថ្ងៃចន្ទ ទី២១ ខែកុម្ភៈ ឆ្នាំ២០២២ អ្នកស្រុកបានប្រទះឃើញសិលាចារឹកថ្មីៗមួយ នៅក្នុងភូមិរំចេក ឃុំត្នោត ស្រុកបាទី ខេត្តតាកែវ។

សិលាចារឹកមួយផ្ទាំងនេះ រកឃើញនៅពេលគ្រឿងចក្រកាយយកដីនៅស្រែរបស់កសិករឈ្មោះ ឡោ ហុន ដែលរស់នៅក្នុងភូមិឃុំខាងលើ។ បន្ទាប់ពីរក្សាទុកនៅផ្ទះមួយយប់ ស្អែកឡើងថ្ងៃអង្គារ ទី២២ ខែកុម្ភៈ ឆ្នាំ២០២២ លោក ឡោ ហុន ក៏បានប្រគល់សិលាចារឹកមួយផ្ទាំងនេះជូនរដ្ឋបាលឃុំត្នោតរក្សាទុក។

សិលាចារឹកនេះចារនៅលើមេទ្វារប្រាសាទ សាងពីថ្មស្រទាប់ (Schiste ardoisier) និងសរសេរជាភាសាខ្មែរបុរាណសម័យមុនអង្គរ មានចំនួន៤បន្ទាត់។ សិលាចារឹកនេះពុំមានចុះកាលបរិច្ឆេទឡើយ ប៉ុន្តែតាមទម្រង់តួអក្សរ ឬបុរាណលេខន៍ (Paleography) យើងអាចដឹងថាចារនៅចន្លោះស.វ.ទី៧-៨។

ថ្វីដ្បិតតែផ្នែកខ្លះនៃអត្ថបទចារឹក បានដាច់បាត់តួអក្សរមួយចំនួន ក៏យើងអាចអានបាននិងយល់អត្ថន័យបានទាំងស្រុង។ ផ្នែកដំបូង គឺជាបញ្ជីរាយតង្វាយរបស់**បោញភវកីត្តិ** ថ្វាយចំពោះទេពព្រះនាម**ស្វយម្ភូ** រួមមានអ្នកបម្រើស្រីប្រុស ស្រែ និងគោ។ ចុងក្រោយជាការរៀបរាប់ឈ្មោះអ្នកបួស ដែលត្រូវធ្វើពិធីស្រង់ទឹកព្រះ។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

## សិលាចារឹករកឃើញថ្មី នៅភូមិរំចេក ឃុំត្នោត

គួររំលឹកផងដែរថា ទេពព្រះនាម**ស្វយម្ភូ** អង្គនេះ ក៏មាននៅក្នុងសិលាចារឹកវត្តត្នោត K.៣៨ ដែលទីតាំងវត្តនេះ ស្ថិតនៅចម្ងាយត្រង់ប្រហែល៤គីឡូម៉ែត្រ ពីទីតាំងរកឃើញសិលាចារឹកភូមិរំចេកនេះផងដែរ។ ទីតាំងដែលរកឃើញសិលាចារឹកនេះពុំឃើញមានសំណល់បុរាណអ្វីឡើយដែលគួរឱ្យកត់សម្គាល់ឡើយ ប៉ុន្តែនៅក្បែរទីតាំងរកឃើញសិលាចារឹកនេះ អ្នកស្រុកបានប្រាប់ថាមានទួលអង្គមួយចំនួនផងដែរ។ សិលាចារឹកនេះ ទំនងជាបានផ្លាស់ប្តូរពីទីតាំងដើម ដែលទំនងជាមិនឆ្ងាយប៉ុន្មានឡើយពីទីតាំងរកឃើញសិលាចារឹកនេះ។

### អំណានអត្ថបទជាអក្សរខ្មែរទំនើប

១- អំ(នោ)[[យិបោ]]ញ៑ភវកីត្តិតវ្រះកម្រតាញ៑ស្វយក៑[1] ក្នុំ[[កុ]]កន្ទិនិ

២- កោនិក៑ កុមាសិក្សុរង៑១ វគំភូ[2] ទាសិ១ វរុទ្រទាសិ ស្រេ ត្នុរិ

៣- បំនោសិទ្ធារស្បិទ្ធិកិគិ ម្រតាញ៑កុមារគាន្តិ[3]១ ម្រតាញ៑ក្មោញ៑កោនិច្នោង៑

៤- ធម្មគាន្តិ[4] សោមភ(វ)

### ប្រែសម្រួលជាភាសាខ្មែរទំនើប

តង្វាយរបស់បោញភវកីត្តិចំពោះព្រះកម្រតាញស្វយម្ភូ។ អ្នកបម្រើ(ព្រះ) កុកន្ទិន និងកូនរបស់នាង(គឺ)កុមាសក្សុរង១ វសម្ភូទាស១ វរុទ្រទាស ស្រេ គោ។ អ្នកបួសដែលទទួលធ្វើពិធីស្រង់ទឹកព្រះគឺម្រតាញកុមារសាន្តិ ម្រតាញក្មោញកោនច្នោង ធម៌សាន្តិ សោមភវ។

### ពន្យល់ពាក្យ

[1] ពាក្យត្រឹមត្រូវជា «ស្វយំភូ/ស្វយម្ភូ»។

[2] ពាក្យត្រឹមត្រូវជា «គំភុ/គម្ភុ»។

[3] សំណេរនៅលើសិលាចារឹក មានទម្រង់ដូចពាក្យ «គាត្តិ»។ ក្នុងសិលាចារឹកនេះ តួអក្សរ «ន» មានទម្រង់ស្រដៀងនឹងអក្សរ «ត» ដែលអ្នកចារទំនងជាច្រឡំចារ «គាន្តិ» ជា «គាត្តិ»។

[4] ដូចកំណត់ជើងទំព័រលេខ៣។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

**អំនោយ៑** — តង្វាយ អំណោយ។

**ពោញ៑** — ឋានន្តរនាមមន្ត្រីសម័យមុនអង្គរ។

**ភវកីត្តិ** — ឈ្មោះមន្ត្រី។

**វ្រះ** — ព្រះ។

**វ្រះកម្រតាញ៑** — ពាក្យសម្គាល់ព្រះ អាទិទេពនាសម័យមុនអង្គរ។ នៅសម័យមុនអង្គរ គេប្រទះឃើញនិយមប្រើឋានន្តរនាម «វ្រះកម្រតាងអញ៑» ច្រើនជាង «វ្រះកម្រតាញ៑»។ ពាក្យ «វ្រះកម្រតាញ៑» ធ្លាប់ឃើញតែ២ដង ប៉ុណ្ណោះ នៅក្នុសិលាចារឹកដែលរកឃើញកន្លងមក និងរកឃើញនៅក្នុងសិលាចារឹកនេះ គឺជាពាក្យទី៥។ ពាក្យ «កម្រតាញ៑» នេះ ច្រើនប្រើជាមួយពាក្យ «ក្បោញ៑» ទៅជា «ក្បោញ៑កម្រតាញ៑» ដែលជាឋានន្តរនាមសម្គាល់ព្រះអាទិទេពនាសម័យមុនអង្គរដែរ។

**ស្វយកុ** — ព្រះនាមទេព, ស្វយម្ភូ(កើតឡើងដោយឯង។)។

**កុ** — ឋានន្តរនាមអ្នកបម្រើភេទស្រី។

**វ៑** — ឋានន្តរនាមអ្នកបម្រើភេទប្រុស។ (វ៑ > វា)

**ស្រេ** — ស្រែ។

**ត្នុរ៑** — គោ។

**បំនោស៑** — អ្នកបួស។

**ទ្មារ៑** — អ្នកទទួល។

**ស្បិទ្និក៑** — សិតទឹក ស្រង់ទឹក។

**គិ◌្** — គឺ។

**ម្រតាញ៑** — ឋានន្តរនាមមន្ត្រីនិងព្រាហ្មណ៍សម័យមុនអង្គរ។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

# បញ្ជីរូបភាព



សំណៅផ្តិតសិលាចារឹកភូមិរំចេក (ផ្តិតដោយ ហ៊ុន ឈុនតេង ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២)



រូបថតសិលាចារឹកភូមិរំចេក (រូបថតៈ ហ៊ុន ឈុនតេង)

អត្ថបទដោយៈ ហ៊ុន ឈុនតេង



រូបថតសិលាចារឹកភូមិរំចេក (រូបថត៖ ហ៊ុន ឈុនតេង)



ទីតាំងរកឃើញសិលាចារឹក (រូបថត៖ ហ៊ុន ឈុនតេង)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



អ្នកភូមិ ដឹកនាំដោយលោក ឃុត វុត្ថា បង្ហាញទីតាំងរកឃើញសិលាចារឹក




ទីតាំងរកឃើញសិលាចារឹកទាក់ទងនឹងព្រះស្វយម្ភូ នៅឃុំត្នោត ស្រុកបាទី (រូបថត៖ Google Earth)

ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក **ឈន ប៊ុនហាក់** អនុប្រធានការិយាល័យបេតិកភណ្ឌនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ ខេត្តតាកែវ, លោក **នៅ ចាន់ណា** អនុប្រធានការិយាល័យសង្គមកិច្ចនិងសុខុមាលភាព នៃរដ្ឋបាលស្រុកបាទី និងរដ្ឋបាលឃុំត្នោត ដែលបានជួយសម្របសម្រួលដល់ការចុះផ្ដិតសំណៅសិលាចារឹកនេះ ព្រមទាំងលោក **ឃុត វុត្ថា** និងសហការី ដែលបានជូនដល់ទីតាំងរកឃើញសិលាចារឹកនេះ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង